ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

**សំណុំរឿងរដ្ឋប្បវេណី**

លេខ៖ ១១៨

ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៣

**សាលដីការដ្ឋប្បវេណី**

លេខ៖ ៣៣ ក្រ V «វ»

ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

នាថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣

## សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ

**ឯកឧត្តម** [redacted] **ប្រធានក្រុមប្រឹក្សា**

**លោកស្រី** [redacted] **ចៅក្រមប្រឹក្សា**

**លោក** [redacted] **ចៅក្រមប្រឹក្សា**

**លោក** [redacted] **ចៅក្រមប្រឹក្សា**

**លោកស្រី** [redacted] **ចៅក្រមប្រឹក្សា**

**ក្រឡាបញ្ជីសវនាការ**

**កញ្ញា សុវណ្ណ ថាវឌ្ឍន៍**

ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់នូវសំណុំរឿងរដ្ឋប្បវេណីលេខ ១១៨ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០២៣ ដែលមាន៖

- ដើមចោទឈ្មោះ [redacted] វឌ្ឍនា ហៅ [redacted] វណ្ណៈ ភេទប្រុស អាយុ៦៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខមន្ត្រីរាជការ មានទីលំនៅ [redacted]។

-មានមេធាវី [redacted] តំណាងដោយអាណត្តិឲ្យដើមចោទ។

-ចុងចម្លើយឈ្មោះ [redacted] យូលីម ភេទប្រុស អាយុ៧៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ និងប្រពន្ធឈ្មោះ [redacted] ស៊ីថាន អាយុ៦៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្នស្ថិត [redacted]។ (ប្តឹងសាទុក្ខ)

**-ខ្លឹមសារនៃការទាមទាររបស់ដើមចោទ ៖**

ដើមចោទបានប្តឹងទាមទារឲ្យតុលាការចេញសាលក្រមដូចខាងក្រោម ៖

១.សុំគ្រប់គ្រងដីទំហំ ១៣ ម៉ែត្រ គុណនឹង ៦៥ ម៉ែត្រ ស្មើនឹង ៨៤៥ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិស្វាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង។

២. សុំទាមទារជំងឺចិត្ត ២០.០០០.០០០ (ម្ភៃលាន)រៀល ពីចុងចម្លើយ។





Scanned with CamScanner

៣.ឱ្យចុងចម្លើយសងសំណងថ្ងៃខាតបង់ពេលវេលានិងជំងឺចិត្តចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក។

**អំពីអង្គហេតុ**

តាមពាក្យបណ្តឹង ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ របស់ដើមចោទឈ្មោះ [redacted] វឌ្ឍនា ហៅ [redacted] វណ្ណៈ បានបញ្ជាក់ថា ដីទំហំ ១៣ម៉ែត្រ គុណ ៦៥ម៉ែត្រ ស្មើនឹង ៨៤៥ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិស្វាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ខ្លួនបានកាន់កាប់ និងប្រើប្រាស់តាំងពីឆ្នាំ១៩៧៩ មករហូតដល់ឆ្នាំ១៩៩៩ ខ្លួនបាន ចាក់ដីបន្ថែមធ្វើផ្ទះ ដែលមានសសរថ្ម ជញ្ជាំងក្តារ ទ្វារបង្អួចឈើ និងប្រក់ស័ង្កសី ដល់ឆ្នាំ២០០៨ ខ្លួនបានជួសជុល ផ្ទះដោយប្តូរដាក់ទ្វារដែកចំនួន ០៤ គ្រឿង រៀបជញ្ជាំងឥដ្ឋ ហើយបានបន្តការថែទាំផ្ទះរហូតដល់បច្ចុប្បន្ននេះ។ ស្រាប់តែនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១២ ឈ្មោះ [redacted] ប៊ុន្នី រួមជាមួយឈ្មោះ [redacted] សុគន្ធ បានមកបញ្ជាឱ្យកម្មករវាយរំលំជញ្ជាំងថ្មជុំវិញផ្ទះ និងបានគាស់ទ្វារដែក ០៤គ្រឿង និងកាប់បំផ្លាញផលដំណាំផ្សេងៗដែលកំពុង ផ្ដើបណ្តាលឱ្យខូចខាតយ៉ាងធ្ងន់ធ្ងរ ។ នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១២ ឈ្មោះ [redacted] យូលីម បានបញ្ជាឱ្យកម្មករ មករៀបឥដ្ឋលើរបងថ្មខ្លួន រួចយកសោរមកចាក់បិទទ្វាររបងចេញចូលផ្ទះខ្លួនតែម្តង ។ ខ្លួនបានដាក់ពាក្យប្តឹងសុំ ចេញដីកាសម្រេចរក្សាការពារទៅតុលាការឱ្យឈ្មោះ [redacted] យូលីម បើកទ្វាររបងចេញចូលផ្ទះខ្លួនវិញ ហើយ តុលាការបានសម្រេចដោយចេញដីកាសម្រេចរក្សាការពារលេខ ១៥៤/២០១២ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១២ បង្គាប់ឱ្យឈ្មោះ [redacted] យូលីម បើកទ្វាររបងដែកចេញចូលផ្ទះខ្លួនវិញ តែរហូតមកដល់ពេលនេះឈ្មោះ [redacted] យូលីម នៅតែរឹងទទឹងមិនព្រមចាក់សោរបើកទ្វាររបងនោះនៅឡើយទេ ។ ហេតុដូចនេះដើម្បីការពារផលប្រយោជន៍របស់ខ្លួន ខ្លួនសុំប្តឹងសុំគ្រប់គ្រងដីទំហំ ១៣ម៉ែត្រ គុណ ៦៥ម៉ែត្រ ស្មើនឹង ៨៤៥ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិស្វាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ជាកម្មសិទ្ធិតទៅ និងសុំឱ្យភាគីចុងចម្លើយទទួលរ៉ាប់រងនូវប្រាក់ប្រដាប់ក្តី និងពន្ធផ្សេងៗក្រៅពីបណ្តឹង ។

-បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ១៦៨/៣៤ (ខ) ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រៃវែង ដែលបានសម្រេច ៖

១. ច្រានចោលពាក្យបណ្តឹង ចុះថ្ងៃទី២៤ ខែតុលា ២០១២ របស់ឈ្មោះ [redacted] វឌ្ឍនា ហៅ [redacted] វណ្ណៈ ទុកជាអសារបង់ ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះត្រូវបានប្រកាសនៅសវនាការជាសាធារណៈ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩ ។ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ត្រូវតែធ្វើឡើងក្នុងរយៈពេល ០១(មួយ)ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រមនេះ ។



Scanned with CamScanner

- បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ០១ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ របស់ដើមចោទឈ្មោះ [redacted] វឌ្ឍនា ហៅ [redacted] វណ្ណៈ មិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១៦៨/៣៤ (ខ) ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តព្រៃវែង ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

- បានឃើញ សាលដីការដ្ឋប្បវេណីលេខ ១៦ក្រ II "ណ" ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេច ៖

១.លុបចោលសាលក្រមរដ្ឋប្បវេណីលេខ ១៦៨/៣៤ (ខ) ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រៃវែង ជាអសារបង់ ។

២.បញ្ជូនពាក្យបណ្តឹង ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ របស់ដើមចោទឈ្មោះ [redacted] វឌ្ឍនា និងសំណុំរឿងរដ្ឋប្បវេណីលេខ ២៦៤ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទៅគណៈកម្មការ សុរិយោដីស្រុកពារាំង ខេត្តព្រៃវែង ។

៣.ប្រាក់ប្រដាប់ក្តីថ្នាក់សាលាដំបូងខេត្តព្រៃវែង និងសាលាឧទ្ធរណ៍ភ្នំពេញ ជាបន្ទុករបស់ដើមចោទ ៥០ ភាគរយ និងសហចុងចម្លើយទទួលបន្ទុក ៥០ ភាគរយ ។

- បានឃើញ បណ្តឹងសាទុក្ខលេខ ៣០២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់ចុងចម្លើយឈ្មោះ [redacted] យូលីម និងប្រពន្ធឈ្មោះ [redacted] ស៊ីថាន មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៦ក្រ II "ណ" ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សាលដីការដ្ឋប្បវេណីលេខ ៣៤៨ «ណ» ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២ របស់តុលាការកំពូល ដែលបានសម្រេចសេចក្តីដូចខាងក្រោម ៖

១-ទទួល បណ្តឹងសាទុក្ខលេខ ៣០២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់សហចុងចម្លើយឈ្មោះ [redacted] យូលីម និងប្រពន្ធឈ្មោះ [redacted] ស៊ីថាន ។

២-បដិសេធ សាលដីការដ្ឋប្បវេណីលេខ ១៦ក្រ II "ណ" ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទាំងមូល ។

៣-បញ្ជូន សំណុំរឿងរដ្ឋប្បវេណីលេខ ១០៣ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទឈ្មោះ [redacted] វឌ្ឍនា ហៅ [redacted] វណ្ណៈ ។

សាលដីកានេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២ ។

**នាពេលទាញហេតុផលដោយផ្ទាល់មាត់**



Scanned with CamScanner

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍សង្ខេបរឿង ។

-ដើមចោទឈ្មោះ [redacted] វឌ្ឍនា ហៅ [redacted] វណ្ណៈ (វត្តមាន) ។

-មេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិអោយដើមចោទ (វត្តមាន) ។

-ចុងចម្លើយឈ្មោះ [redacted] យូលីម និងប្រពន្ធឈ្មោះ [redacted] ស៊ីថាន (វត្តមាន) ។

## ការអះអាងរបស់ភាគីដើមចោទ

-ដើមចោទឈ្មោះ [redacted] វឌ្ឍនា ហៅ [redacted] វណ្ណៈ បានធ្វើសេចក្ដីថ្លែងការណ៍នាពេលសវនាការថា ៖ ខ្លួនមានទីលំនៅបច្ចុប្បន្ននៅ [redacted] ខ្លួនបានទៅរស់នៅលើដីវិវាទតាំងពីឆ្នាំ ១៩៧៩ ដោយបានសង់ផ្ទះប្រក់ស័ង្កសី ជញ្ជាំងថ្មមានទ្វារដែកចំនួន០៤ផ្ទាំង រហូតដល់បច្ចុប្បន្ន ។ ខ្លួនរស់នៅភូមិស្វាយពល តាំងពីឆ្នាំ១៩៧៩ ដល់ឆ្នាំ ១៩៨២ ទើបខ្លួនចេញមករៀននុកទ័រនៅភ្នំពេញ រហូតសព្វថ្ងៃខ្លួនរស់នៅរាជធានីភ្នំពេញ នៅអំឡុងចន្លោះឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៨២ ខ្លួនកាន់កាប់ដីវិវាទ រស់នៅលើដីនោះ និងធ្វើស្រែលើដីនោះ ដែលមានផ្ទះនៅចំកណ្ដាល ។

-មេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិអោយដើមចោទ បានធ្វើសេចក្ដីថ្លែងការណ៍ថា ៖ ដីទំហំ១៣ម៉ែត្រ គុណនឹង ៦៥ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិស្វាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃ វែង គឺជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] វឌ្ឍនា ហៅ [redacted] វណ្ណៈ ពិតប្រាកដមែន ដោយមានប្រវត្តិ និងកិរិយាកាន់កាប់តាំងពីឆ្នាំ១៩៧៩ មក ដោយលោកបានគ្រប់គ្រងនិងអភិវឌ្ឍន៍ដីនោះដែលអតីតជាស្រែជម្រៅ ដោយមានការចាក់ដីបន្ថែមសង់ផ្ទះដែលមានសសរថ្ម ជញ្ជាំងក្ដារ ទ្វារបង្អួចឈើ និងប្រក់ស័ង្កសី និងបានធ្វើរបងដែក ដាក់នៅច្រក ចេញចូលដីដោយដាក់ក្បាច់ឈ្មោះ NAK និងសង់ព័ទ្ធដោយរបងឈើ ព្រមទាំងមានបោះបង្គោលថ្មសម្គាល់ព្រំដីផង ដែរ។ ក្រោយមកទៀត ឈ្មោះ [redacted] វឌ្ឍនា ហៅ [redacted] វណ្ណៈ បានធ្វើពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លីចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៦ (ឯកសារទី១) ដោយមានហត្ថលេខា និងត្រាបញ្ជាក់ពីមេឃុំរកាឈ្មោះ [redacted] ហាយ និង មេភូមិស្វាយពល ឈ្មោះ [redacted] អុន បានចំណារជូនទៅអភិបាលស្រុកពារាំងទទួលស្គាល់ដីនេះជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] វឌ្ឍនា ហៅ [redacted] វណ្ណៈ ដែលបានសង់ផ្ទះនៅក្នុងបរិវេណរបងតាំងពី ឆ្នាំ១៩៧៩ រហូតមកដល់សព្វថ្ងៃដោយមានទ្វាររបងដែកអក្សរ NAK ជាច្រកចេញចូលពិតប្រកដមែន។ ក្រោយមកនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៧ អភិបាលស្រុកពារាំង លោក [redacted] សារៈ បានចេញប្រកាសបិទផ្សាយជាសាធារណៈតាមពាក្យស្នើសុំកាន់កាប់ដីធ្លី អំពីការស្នើ សុំកាន់កាប់និងប្រើប្រាស់ដីធ្លីរបស់ឈ្មោះ [redacted] វឌ្ឍនា ហើយអញ្ជើញបុគ្គលដែលមានទំនាស់ផលប្រយោជន៍ប្ដឹងតវ៉ា (ឯកសារទី២) ហើយដល់កាលកំណត់ផុតថ្ងៃប្ដឹងតវ៉ា ជាក់ស្ដែងមិនមានបណ្ដឹងតវ៉ាទៅលើសេចក្ដីប្រកាសដែល បានបិទផ្សាយជាសាធារណៈនោះឡើយ ក្រោយមកដើមចោទឈ្មោះ [redacted] វឌ្ឍនា ហៅ [redacted] វណ្ណៈ ក៏បន្តការថែរក្សាគ្រប់គ្រង និងកាន់កាប់ទៅលើដីនោះបន្តទៀត។ ស្រាប់តែថ្ងៃទី០១ ខែមេសា ឆ្នាំ២០១២ ឈ្មោះ [redacted] ប៊ុន្នី (កូនប្រសារ) ឈ្មោះ



Scanned with CamScanner

[redacted] យូលីម) បានបញ្ជាឲ្យកម្មករវាយរលំជញ្ជាំងថ្មជុំវិញផ្ទះ និងគាស់ទ្វារដែកចំនួន០៤ គ្រឿង រួមទាំងកាប់បំផ្លាញផលដំណាំផ្សេងៗ បណ្តាលឲ្យខូចខាតយ៉ាងធ្ងន់ធ្ងរ (ឯកសារទី៣)។ ដោយមានការរំលោភបំពានបែបនេះទើបឈ្មោះ [redacted] វឌ្ឍនាបានដាក់ពាក្យសុំដីការក្សាការពារទៅសាលាដំបូងខេត្តព្រៃវែង ហើយត្រូវបាន តុលាការសម្រេចសេចក្តីបើកទ្វារបង ដូចមានបញ្ជាក់ក្នុងដីកាសម្រេចរក្សាការពារចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តព្រៃវែង (ឯកសារទី៤)។ ក្រោយមកឈ្មោះ [redacted] យូលីម មិនព្រមបញ្ឈប់អំពើរំលោភបំពានរបស់ខ្លួនឡើយ ទើបឈ្មោះ [redacted] វឌ្ឍនា បានដាក់បណ្តឹងអង្គសេចក្តីទៅសាលាដំបូងខេត្តព្រៃវែងនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ ហើយត្រូវបានលោក ចៅក្រម [redacted] ជាអ្នកកាន់ សំណុំរឿងនោះក៏បានចុះធ្វើការវាស់វែងជាក់ស្តែង និង បានឯកភាពគ្នាគ្រប់ភាគី ទាំងអស់ផ្តិតមេដៃ នៅលើកំណត់ហេតុវាស់វែងជាក់ស្តែងទាំងអស់គ្នា (ឯកសារទី៥) ដោយមិនមានភាគីណាជំទាស់ឡើយ ដោយក្នុងកំណត់ហេតុមានភ្ជាប់គំនូសព្រាង បង្ហាញអំពីប្លង់គូសដោយប្រធានការិយាល័យភូមិបាល ស្រុកពារាំង ឈ្មោះ [redacted] ផលលៀង ដែលមានម្ចាស់កម្មសិទ្ធិនៃដីឈ្មោះ [redacted] វឌ្ឍនា ហៅ [redacted] វណ្ណៈ កាន់កាប់ ទំហំ១៣ម៉ែត្រ គុណនឹង៦៥ម៉ែត្រ ក្នុងនោះក៏មានការផ្តិតមេដៃទទួលស្គាល់ដោយ ចុងចម្លើយឈ្មោះ [redacted] យូលីម ព្រមទាំងភាគីដែលពាក់ព័ន្ធទាំងអស់ផងដែរ (ឯកសារទី៥)។ ក្រោយមកទៀត នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ លោកចៅក្រម [redacted] ដែលជាចៅក្រមទទួលបន្ទុកបន្តនៅក្នុងសំណុំរឿងនេះបានចុះពិនិត្យវាស់វែងដីទំនាស់ ម្តងទៀត ក៏ពុំមានកែប្រែនូវគំនូសរបស់ប្រធានការិយាល័យភូមិបាលស្រុកឡើយដូចមានចែងក្នុងកំណត់ហេតុចុះ ពិនិត្យនិងវាស់វែងទីតាំងដីទំនាស់ជាក់ស្តែងចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រៃវែង (ឯកសារទី៦)។ ស្រាប់តែមកដល់ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០ ឈ្មោះ [redacted] យូលីម និង ឈ្មោះ [redacted] បុន្នី (កូនប្រសារ) បានចាក់ដីធ្វើអោយលិចរបងទ្វារដែកក្បាច់អក្សរ NAK ហើយនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ឈ្មោះ [redacted] យូលីម និង ឈ្មោះ [redacted] បុន្នី បានវាយរបងថ្មអស់ប្រវែង ២៩ ម៉ែត្រ និងបានសាងសង់របងឈើថ្មី។ ក្រោយមកទៀតថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០២០ ឈ្មោះ [redacted] យូលីម និង ឈ្មោះ [redacted] បុន្នី បានសង់របងថ្មីធ្វើពីស័ង្កសីព័ទ្ធដីនោះ និងបិទទ្វារច្រកចេញចូល ដែលសាលាដំបូងខេត្តព្រៃវែងបានសម្រេចបើកទ្វារនេះតាមរយៈដីការក្សាការពាររួចម្តងមកហើយ។ ដូច្នេះ ឈ្មោះ [redacted] វឌ្ឍនា បានដាក់ពាក្យសុំដីកាសម្រេចរក្សាការពារមួយទៀត ដើម្បីហាមឃាត់ឈ្មោះ [redacted] យូលីម មិនឲ្យធ្វើសកម្មភាពរំលោភបំពានទៀត ហើយត្រូវបានសាលាដំបូងខេត្តព្រៃវែងចេញដីកាសម្រេចរក្សាការពារលេខ ៨៧៩ ដស.រណ សម្រេចហាមឃាត់ឈ្មោះ [redacted] យូលីម មិនឲ្យធ្វើសកម្មភាពសាងសង់ និងសកម្មភាពផ្សេងៗនៅ លើដីវិវាទតថភាពនៃច្បាប់ សបញ្ជាក់បានថា ដីទំហំក្បាលដី១៣ម៉ែត្រ គុណនឹង៦៥ម៉ែត្រ ដែលមានទីតាំងស្ថិតនៅ ភូមិស្វាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ពិតជាសិទ្ធិកម្មសិទ្ធិរបស់ ឈ្មោះ [redacted] វឌ្ឍនា ហៅ [redacted] វណ្ណៈ ពិតប្រាកដមែន។ សម្អាងហេតុដែលលើកឡើងដោយបែបនេះគឺ ដោយផ្អែកតាមតថភាពជាក់ស្តែងគាំទ្រដោយភស្តុតាងដែលមានក្នុងសំណុំរឿងដែលបង្ហាញពីទំនាក់ទំនងគតិយុត្ត ដែលអាចអោយជឿ



Scanned with CamScanner

ចោទធ្វើលទ្ធកម្មនៃកម្មសិទ្ធិ តាមច្បាប់ភូមិបាលឆ្នាំ២០០១។ យោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា ២៩ មាត្រា៤៣ និងមាត្រា ៣៨ លទ្ធកម្មនៃកម្មសិទ្ធិអាចធ្វើទៅបានត្រូវស្របតាមលក្ខខណ្ឌដែលជនម្នាក់បានកាន់កាប់ស្របតាមច្បាប់ក្នុងកំឡុង ពេលក្រោយឆ្នាំ១៩៧៩ និង មុនថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដោយមានកិរិយានៃការកាន់កាប់ពិតប្រាកដ ដោយសុចរិត គ្មានហិង្សា ដោយមានការដឹងឮជាសាធារណៈ នោះបុគ្គលនោះអាចធ្វើការដាក់ពាក្យស្នើសុំដើម្បីជាម្ចាស់ កម្មសិទ្ធិដីធ្លីផ្លូវការ។ ម្យ៉ាងវិញទៀត ក្រមរដ្ឋប្បវេណី មាត្រា១៦២ កថាខណ្ឌទី២ ក៏បានចែងអំពីអាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុទៅជនដែលបានកាន់កាប់អចលនវត្ថុ ដោយសន្តិវិធី និងដឹងឮជាសាធារណៈក្នុងរយៈពេល ១០ (ដប់) ឆ្នាំ បើជននោះសុចរិត និងគ្មានកំហុសនៅពេលដែលខ្លួនចាប់ផ្តើមកាន់កាប់។ ផ្អែកតាមគតិច្បាប់ដែលលើកឡើងខាងលើ ឈ្មោះ [redacted] វឌ្ឍនា ហៅ [redacted] វណ្ណៈ បានកាន់កាប់តាំងពីឆ្នាំ១៩៧៩ មកដល់ បច្ចុប្បន្នពិតប្រាកដមែនជាក់ស្តែងតាមរយៈការអភិវឌ្ឍន៍ ថែរក្សា គ្រប់គ្រង មេឃុំរកា ឈ្មោះ [redacted] ហាយ និងមេភូមិស្វាយពលតាមរយៈចំណារបញ្ជាក់ប្រវត្តិនៃការកាន់កាប់ដីរបស់ដើមចោទ និងកាន់កាប់ ដោយមានការដឹងឮ ពីក្នុងពាក្យស្នើសុំកាន់កាប់ដីធ្លីចុះថ្ងៃ២៣ ខែកញ្ញា ឆ្នាំ២០០៦ របស់ដើមចោទ និងលិខិតបញ្ជាក់ប្រវត្តិដីចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១២ របស់មេឃុំរកា ឈ្មោះ [redacted] ហាយ។ លើសពីនេះតាមរយៈកំណត់ហេតុចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ដែលមានការចូលរួមចុះវាស់វែងផ្ទាល់ដោយ ចៅក្រម [redacted] រួមទាំងគំនូសព្រាងភ្ជាប់បង្ហាញអំពីប្លង់ដែលគូសនឹងធ្វើកំណត់ហេតុដោយប្រធានការិយាល័យភូមិបាលស្រុកពារាំង លោក [redacted] ផលលៀងសបញ្ជាក់យ៉ាងច្បាស់ និងមិនអាចប្រកែកបានថា ភាគីសហចុងចោទ ឈ្មោះ [redacted] យូលីម ពិតជាបានទទួលស្គាល់អំពីសិទ្ធិកម្មសិទ្ធ និងការកាន់កាប់ដីរបស់ឈ្មោះ [redacted] វឌ្ឍនា (ហៅ [redacted] វណ្ណៈ) ដែលមានទំហំ១៣ម៉ែត្រ គុណនឹង ៦៥ម៉ែត្រ ដោយមានផ្តិតស្នាមមេដៃរបស់ខ្លួនពិតប្រាកដមែន ។ ហេតុដូច្នេះផ្អែកតាមអាជ្ញាយុកាលនៃការកាន់កាប់តាមច្បាប់ភូមិបាលឆ្នាំ២០០១ និងក្រមរដ្ឋប្បវេណី ឈ្មោះ [redacted] វឌ្ឍនា ពិតជាបានបំពេញគ្រប់លក្ខខណ្ឌទាំងអស់ ក្នុងការទទួលបានលទ្ធកម្មនៃកម្មសិទ្ធិទៅលើដីដែលមានទំហំ ១៣ម៉ែត្រ គុណនឹង ៦៥ម៉ែត្រ ពិតប្រាកដមែន។ ចំពោះលិខិតបញ្ជាក់លេខ ៖ ១១០៥/២០១២ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១២ របស់មេភូមិ [redacted] សុផល ដែលមានខ្លឹមសារអះអាងថា ឈ្មោះ [redacted] វឌ្ឍនា (ហៅ [redacted] វណ្ណៈ) ពុំធ្លាប់រស់នៅទីតាំងដីទំនាស់នោះជា ការបញ្ជាក់ផ្ទុយពីលិខិតបញ្ជាក់ប្រវត្តិដីលេខ៖ ១០៨៤/២០១២ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២ ចេញដោយ មេឃុំ [redacted] (ឯកសារទី៨)។ ទម្រង់លិខិតបញ្ជាក់របស់មេភូមិកាន់ដំណែងថ្មីឈ្មោះ [redacted] សុផល លេខ ៖ ១១០៥/២០១២ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១២ មានខ្លឹមសារមិនស៊ីសង្វាក់គ្នាជាមួយនឹងតថភាពជាក់ស្តែង ហើយមានឋានានុក្រមទាបជាងលិខិតបញ្ជាក់ប្រវត្តិដីរបស់មេឃុំ [redacted] លេខ៖ ១១០៨៤/២០១២ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២ ផងដែរ។ លើសពីនេះ ដើមចោទក៏បានចេញលិខិតបដិសេធ ជូនទៅមេឃុំរកាផងដែរ បន្ទាប់ពីបានទទួលដំណឹងភ្លាម។ សេចក្តីថ្លែងការណ៍អំពីអង្គហេតុ អង្គច្បាប់ និងដោយពិនិត្យលើភស្តុតាងពាក់ព័ន្ធនានាក្នុងសំណុំរឿង ខាងលើឃើញ



Scanned with CamScanner

ថា ភាគីដើមចោទពិតជាមានមូលដ្ឋានគតិយុត្តិគ្រប់គ្រាន់ដែលគាំទ្រដល់ការទាមទាររបស់ខ្លួន ហេតុនេះសូមសំណូមពរតុលាការមេត្តាចេញសេចក្តីសម្រេច៖ ១-លុបចោលសាលក្រមលេខ ៖ ១៦៨/៣៤(ខ) ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០១៩ របស់សាលាដំបូង ខេត្តព្រៃវែង។ , ២. បញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិកម្មសិទ្ធិលើអចលនវត្ថុដី មានទំហំ ១៣ ម៉ែត្រ x ៦៥ ម៉ែត្រ ដែលមាន ទីតាំងស្ថិតនៅភូមិស្វាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ជាកម្មសិទ្ធិរបស់ភាគីដើមចោទ ឈ្មោះ [redacted] វឌ្ឍនា។ , ៣- បង្គាប់ឲ្យរុះរើរាល់សំណង់ទាំងអស់ដែលភាគីចុងចម្លើយឈ្មោះ [redacted] យូលីម និង ឈ្មោះ [redacted] ស៊ីថាន បានសាងសង់នៅលើដី មានទំហំ ១៣ម៉ែត្រ x ៦៥ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិស្វាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង , ៤-បង្គាប់អោយសហចុងចម្លើយឈ្មោះ [redacted] យូលីម និង ឈ្មោះ [redacted] ស៊ីថាន ប្រគល់ការកាន់កាប់លើដី ដែល មានទំហំ ១៣ម៉ែត្រ x ៦៥ម៉ែត្រដែលមានទីតាំងស្ថិតនៅភូមិស្វាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ឲ្យមកភាគីដើមចោទវិញ , ៥-បង្គាប់ឲ្យចុងចម្លើយសងជម្ងឺចិត្ត ការខាតបង់ពេលវេលា និងសេវាកម្មច្បាប់ សរុបទឹកប្រាក់ USD ១០.០០០ (មួយម៉ឺនដុល្លារអាមេរិក) មកឲ្យដើមចោទឈ្មោះ [redacted] វឌ្ឍនា និង ៦-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

<u>ការអះអាងរបស់ភាគីចុងចម្លើយ</u>

-ចុងចម្លើយឈ្មោះ [redacted] យូលីម និងប្រពន្ធឈ្មោះ [redacted] ស៊ីថាន បានធ្វើសេចក្តីថ្លែងការណ៍ថា ៖ ក. គំនូសព្រាងអង្កេតដីដែលលោកចៅក្រម [redacted] ចុះវាស់វែងកាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ ២០១៦ បានបញ្ជាក់ថា ដី [redacted] យូលីម តាមការអះអាងរបស់គាត់ (ទាំងអស់), ខ- ឈ្មោះ [redacted] វឌ្ឍនា ធ្លាប់បានរស់នៅដូចការអះអាងក្នុងចំនុចទី១ខាងលើ តែមិនមែននៅលើដី ១៣ ម៉ែត្រ គុណ ៦៥ម៉ែត្រទេ កាលនោះ ដីនេះជាស្រែ ដែលខ្លួនបានធ្វើពុំមានសំណង់អ្វីទេ , គ- លិខិតលេខ ១១០៥/២០១២ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២ របស់មេឃុំរកា បានបញ្ជាក់ថា ផ្ទះលេខ៥៤៧ ក្រុមទី៥០ របស់ឈ្មោះ [redacted] វឌ្ឍនា (ហៅវណ្ណៈ) នេះពុំមានច្បាប់សាងសង់អ្វីទេ។ តាមខ្លួនដឹងពីមុនមកគេសាងសង់សម្រាប់ធ្វើជា ទីស្នាក់ការបក្សរបស់គណៈបក្សសេរីនិយម ព្រះពុទ្ធ សាសនា លើដីរបស់ឈ្មោះ [redacted] យូលីម ដែលគ្រប់គ្រងតាំងពីឆ្នាំ១៩៧៩មក ដល់គណបក្សសេរី និយមព្រះពុទ្ធសាសនានោះឈប់ដំណើរការទៅ ឈ្មោះ [redacted] វឌ្ឍនា បានមកចុះឈ្មោះក្នុងសៀវភៅ (ក១) ថាជាផ្ទះរបស់ខ្លួនក្នុងឆ្នាំ១៩៩៩ ជាមួយមេភូមិមុន ( [redacted] អ៊ិន) មកដល់ឆ្នាំ២០០៨ ការ ស្រង់ចូលសៀវភៅ (ក១)ថ្មី ខ្លួនបានលុបឈ្មោះ [redacted] វឌ្ឍនា ចេញ ដោយយកលេខផ្ទះ និងក្រុម ខាងលើនេះ ដាក់ឱ្យប្រជាពលរដ្ឋដែលរស់នៅទីតាំងផ្សេងទៀត ព្រោះ [redacted] វឌ្ឍនា ពុំធ្លាប់រស់នៅអាសយដ្ឋានខាងលើនេះទេ ម្យ៉ាងស្នាក់ការខាងលើនេះស្ថិតក្រោមការគ្រប់គ្រងរបស់ឈ្មោះ [redacted] យូលីម។ ក្រោយឆ្នាំ ១៩៧៩ ខ្ញុំបាទនិងគ្រួសារបានត្រឡប់មករស់នៅលើដីខាងលើ ដែលគ្រួសារខ្លួនធ្លាប់រស់នៅកាលពីសង្គម ដោយមានឯកសារសម្គាល់ដូចជា ប័ណ្ណបុគ្គលិកសិក្សា ប័ណ្ណសហជីពអត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅនិងសៀវភៅគ្រួសារ ឆ្នាំមួយពាន់ប្រាំបួនរយប៉ែតសិបជាង កសិកម្មស្រុកបានមកដកហូត ដីខាងក្រោយ ដែលមានក្បាល ៤១

ម៉ែត្រ ជម្រៅ ៤០ម៉ែត្រ ទៅធ្វើស្រែផ្ទាល់ខ្លួន ក្រោយមកខ្លួនបានទៅជួប លោកអភិបាលស្រុកដើម្បីយកដីស្រែនេះមកគ្រប់គ្រងវិញ លោកអភិបាលស្រុកជាអតីតគ្រូបង្រៀនពីឆ្នាំ ១៩៧១ - ១៩៧៦ ជាមួយគ្នា។ ឆ្នាំ១៩៩៨ លោក [redacted] មូលី បានឱ្យខ្លួនសង់ទីស្នាក់ការបក្សដំបូលស័ង្កសី ជញ្ជាំងឈើលាយថ្ម លើដីស្រែនេះ ដើម្បីជួលឱ្យគាត់បើកធ្វើគណៈបក្ស។ ដីរាងអក្សរអិល (L) ក្បាល ១៣,៥០ម៉ែត្រ (បែរមុខទៅត្បូង) ទល់នឹងផ្លូវ ៨A ខ្ញុំសាងសង់ផ្ទះតាំងក្រោយ ថ្ងៃរំដោះ៧មករា ឆ្នាំ១៩៧៩ រើផ្ទះពីវត្តមក។ ជ្រុងម្ខាងទៀត (បែរមុខទៅកើត) ទល់នឹងផ្លូវទៅឃុំព្រៃស្រឡិត ឆ្នាំ១៩៩៨ ខ្លួនសង់ទីស្នាក់ការធ្វើពីដំបូលស័ង្កសី ជញ្ជាំងឈើលាយថ្ម ទំហំ ៤ម៉ែត្រ គុណ ៧ម៉ែត្រ ដើម្បី ជួលឱ្យ ឯកឧត្តម [redacted] មូលី ឆ្នាំដំដែល ក្រោយការបោះឆ្នោត ខែកក្កដា គណៈបក្ស សេរីនិយមព្រះពុទ្ធសាសនាក៏ឈប់ដំណើរការ ។ បន្ទាប់ពីផ្លូវលេខ ៨A បានសាងសង់ជាផ្លូវជាតិ និងផ្លូវលំទៅឃុំព្រៃស្រឡិតត្រូវបានលើកកម្ពស់ ក្រាលកៅស៊ូ អ្នកជិតខាងចាក់ដីឡើងខ្ពស់ ដីរបស់ខ្លួនទាបត្រូវទឹកលេច ខ្លួនក៏បានចាក់បំពេញជារៀងរាល់ឆ្នាំ ធ្វើឱ្យដំណាំងាប់ជាបន្តបន្ទាប់ (ដល់បច្ចុប្បន្នចាក់កម្ពស់ប្រហែលពីរម៉ែត្រជាង) បានដាំ ឡើងវិញជាបន្តបន្ទាប់។ រូបថតដើមដូងដែលខ្លួនបានដាំ និងកំពុងអាស្រ័យផលរហូតដល់បច្ចុប្បន្នឆ្នាំ១៩៧១ ដល់ ឆ្នាំ១៩៧៦ ខ្លួននិងគ្រួសារ បានរស់នៅ កាន់កាប់ដីមួយកន្លែងដែលមានរាងជាអក្សរអិល (L) ស្ថិតនៅភូមិស្វាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ដែលមានព្រំប្រទល់ខាងត្បូងជាប់ផ្លូវ៨A មានប្រវែង ១៣៥០ម៉ែត្រ ជម្រៅ៨២ម៉ែត្រ។ ខាងកើតជាប់ផ្លូវទៅសង្កាត់ព្រៃស្រឡិត មានប្រវែង ៤១ម៉ែត្រ និងជម្រៅ ៧៦ម៉ែត្រ មកទល់សព្វថ្ងៃ កន្លែងដែលប្ដី ប្រពន្ធខ្លួនរស់នៅគឺជាតំបន់រំដោះ។ ចុងឆ្នាំ ១៩៧៦ គ្រួសារត្រូវទៅរស់នៅក្នុងវត្តស្វាយពល ក្នុងភូមិស្វាយពល ឃុំរការ ស្រុកពារាំងដដែល មានតែគ្រួសារខ្លួនមួយគត់ដែលបានចេញក្រោយគេ ព្រោះប្រពន្ធកូនខ្ចី ប្ដីជាបុគ្គលិកវប្បធម៌។ គ្រួសារប្រជាជនឯទៀតត្រូវជំលៀសទៅរស់នៅសង្កាត់ផ្សេងៗ ដោយកំណត់ទីកន្លែង ស្វាយពលជាទីប្រជុំជន អង្គការមិនឱ្យប្រជាជនរស់នៅបានទេ។ឆ្នាំ ១៩៨៩រដ្ឋឱ្យប្រជាជនដាក់ពាក្យសុំកាន់កាប់ដីភូមិ និងដីស្រែដែលបានកាន់កាប់។ ថ្ងៃ២០ ខែតុលា ឆ្នាំ ១៩៩០ រដ្ឋបានចែកបង្កាន់ដៃដីភូមិចុះលេខ ៥៥៩៤ និង៥៥៩៥ និងបង្កាន់ដៃដីស្រែលេខ៥៥៩៦ មានឈ្មោះខ្លួននិងប្រពន្ធ។ ឆ្នាំ១៩៩២ ផ្ទះចាស់មានសភាពទ្រុឌទ្រោមក៏រុះរើសង់ថ្មីកម្ពស់ពីរជាន់ដំបូលប្រក់ក្បឿង មានទំហំ ៨ម៉ែត្រ x ១២ម៉ែត្រ។ (ដូចមានរូបថតភ្ជាប់ជាមួយ) ឆ្នាំ១៩៩៨ ក្រោយគណៈបក្ស លោកតា [redacted] ឈប់ដំណើរការ លោក [redacted] ម៉ូលី បានឱ្យខ្លួនសាងសង់ ទីស្នាក់ការមួយធ្វើពីជញ្ជាំងឈើលាយថ្ម ប្រក់ស័ង្កសី ដើម្បីជួលធ្វើជាទីស្នាក់ការ គណៈបក្សសេរីនិយមព្រះពុទ្ធ សាសនា របស់គាត់ នៅព្រំខាងកើតជាប់ផ្លូវលំទៅឃុំព្រៃស្រឡិត ទំហំ ៤ម៉ែត្រ គុណនឹង ៧ម៉ែត្រ ក្រោយមកខ្លួនបានធ្វើ របងបង្គោលថ្ម-របារលួស លើព្រំខាងកើត និងមួយផ្នែកនៃព្រំខាងជើងទីស្នាក់ការ។ ឆ្នាំ ២០០៣ ខ្លួនជួលផ្ទះឱ្យធនាគារអេស៊ីលីដា ក្នុងតំលៃ ២.២០០$ (ពីរពាន់ពីររយដុល្លាអាមេរិក) ក្នុងមួយឆ្នាំ និងសង់បន្តជាប់ពីក្រោយផ្ទះចាស់ប្រវែង ៨,៥០ម៉ែត្រ បន្ថែមសម្រាប់គ្រួសារខ្លួនរស់នៅ និងជួលឱ្យបុគ្គលិកធនាគារ ពេទ្យ អង្គការ ។ល។ តាំងពីបានកាន់កាប់មក ខ្លួនសាងសង់របងជាច្រើនដង ដោយធ្វើពីឫស្សី ធ្វើពីជំនៀឈើ ធ្វើពីបង្គោល

ថ្មព័ទ្ធលួសបន្លា ធ្វើពីឥដ្ឋ ចុងក្រោយព្រំខាងកើតធ្វើពីស័ង្កសី ដោយរបងថ្មចាស់ត្រូវកងវិស្វកម្មរុញចេញ ព្រោះវាស្ថិតនៅលើចំណីផ្លូវព្រំខាងត្បូងក៏ត្រូវក្រុមហ៊ុនរុញចេញ ដោយពង្រីកផ្លូវ ៨A ។ ខ្លួនមិនសុខចិត្តនឹងសាលដីកាលេខ ១៦ ក្រ-ណ ២៧/-៩-២១ ចុះថ្ងៃទី២៧ ខែ៩ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញទេ ដោយហេតុថា ខ្លួននិងក្រុមគ្រួសារជាអ្នកកាន់កាប់ និងរស់នៅអាស្រ័យផលលើដីនោះតាំងពីឆ្នាំ១៩៧៩ មកម្លេះ រហូតដល់ពេលនេះមានរយៈពេលជាង៤០ឆ្នាំមកហើយ។ (ដូចមានរូបថតភ្ជាប់ជាមួយ) ។ ភាគីសហចុងចម្លើយពុំដែលធ្លាប់បានរស់នៅ ឬកាន់កាប់ដីខាងលើទេ មានអាជ្ញាធរមូលដ្ឋានជាអ្នកដឹងលឺ និង បានចូលទៅបំភ្លឺដោយផ្ទាល់នៅសាលាដំបូងខេត្តព្រៃវែង កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩។ ឈ្មោះ [redacted] វឌ្ឍនា បានបញ្ជាក់ហើយបញ្ជាក់ទៀតថាខ្លួនរស់នៅស្នាយពលឆ្នាំ ១៩៧៩ ដល់ឆ្នាំ១៩៨ រួចចេញទៅរៀនទុកទ័រនៅក្រុងភ្នំពេញ នេះសបញ្ជាក់ឲ្យច្បាស់ថា ឈ្មោះ [redacted] វឌ្ឍនា រស់នៅបានតែ ០៣ ឆ្នាំទេ ហើយគាត់បានបោះបង់ការកាន់កាប់ ចេញទៅរៀនទុកទ័រនៅក្រុងភ្នំពេញ នេះបើតាមការ អះអាងរបស់គាត់។ តែរឿងការពិតគឺ ឈ្មោះ [redacted] វឌ្ឍនា ពុំបានរស់នៅលើទីតាំងដីរបស់ខ្លួនទេ។ ខ្លួនសូមឲ្យតុលាការសម្រេចច្រានចោលពាក្យបណ្តឹងចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] វឌ្ឍនា ហៅ [redacted] វណ្ណៈ , ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ និងស្នើសុំឲ្យសងសំណងសេវាមេធាវី ជម្ងឺចិត្ត ផលប៉ះពាល់លើកិត្តិយសសេចក្តីថ្លៃថ្នូរ ពេលវេលានិងសោហ៊ុយ ផ្សេងៗ ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លាអាមេរិក។

**សាលាឧទ្ធរណ៍យល់ឃើញថា៖**

១/. តុលាការកំពូលបានចេញសាលដីការដ្ឋប្បវេណីលេខ ៣៤៨ «ណ» ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២ ដោយបានសម្រេចបដិសេធសាលដីការដ្ឋប្បវេណីលេខ ១៦ក្រ II "ណ "ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ហើយបញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ១០៣ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឡើងវិញ ។ ដូចនេះ ក្រុមប្រឹក្សាជំនុំជម្រះសាលាឧទ្ធរណ៍ភ្នំពេញ អាចទទួលជំនុំជម្រះលើសំណុំរឿងរដ្ឋប្បវេណីលេខ ១១៨ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៣ របស់សាលាឧទ្ធរណ៍ភ្នំពេញ ជាសមត្ថកិច្ច អនុលោមតាមបញ្ញត្តិមាត្រា ២៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២/. តុលាការកំពូលបានសំអាងហេតុថា ការដែលសាលាឧទ្ធរណ៍ភ្នំពេញ សម្រេចលុបចោលសាលក្រមរដ្ឋប្បវេណីលេខ ១៦៨/៣៤ (ខ) ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រៃវែង ជាអសារបង់ ហើយបញ្ជូនពាក្យបណ្តឹង ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ របស់ដើមចោទឈ្មោះ [redacted] វឌ្ឍនា និងសំណុំរឿងរដ្ឋប្បវេណីលេខ ២៦៤ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទៅគណៈកម្មការសុរិយោដី ស្រុកពារាំង ខេត្តព្រៃវែង ដោយសំអាងលើខ្លឹមសារគ្រេទី២ នៃ មាត្រា ១ និងមាត្រា ២ នៃប្រកាសអន្តរក្រសួងស្តីពីការកំណត់ភារកិច្ចតុលាការ និងគណៈកម្មការសុរិយោដី ពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី នោះជាការមិនត្រឹមត្រូវទេ ពីព្រោះ



Scanned with CamScanner

ការបញ្ជូនសំណុំរឿងវិវាទដីធ្លី ដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ នៃប្រកាសអន្តរក្រសួងខាងលើ គឺសម្រាប់តែសមត្ថកិច្ចរបស់សាលាដំបូង ហើយមានគូភាគីតវ៉ាតែប៉ុណ្ណោះ ប៉ុន្តែករណីនេះ សាលាដំបូងបានចាត់ការសំណុំរឿងវិវាទដីធ្លី នេះទៅតាមលំហូរនៃក្រមនីតិវិធីរដ្ឋប្បវេណីត្រឹមត្រូវរួចហើយៗគូភាគីក៏មិនបានតវ៉ាពីសមត្ថកិច្ចផងដែរ ។ ដូច្នេះ អនុលោមតាមស្មារតីមាត្រា ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បីសាលាឧទ្ធរណ៍ភ្នំពេញ ធ្វើការជំនុំជម្រះលើសំណុំរឿងរដ្ឋប្បវេណីនេះ ។ តុលាការកំពូល យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១៦ ក្រ" "ណ "ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចមកនេះ ខុសនឹងគតិច្បាប់។

៣/. ការដែលដើមចោទ [redacted] វឌ្ឍនា ហៅ [redacted] វណ្ណៈ និងមេធាវីតំណាងដោយអាណត្តិ ស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេច៖១.លុបចោលសាលក្រមលេខ ៖ ១៦៨/៣៤(ខ) ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រៃវែង , ២. បញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិកម្មសិទ្ធិលើអចលនវត្ថុដី មានទំហំ ១៣ ម៉ែត្រ x ៦៥ ម៉ែត្រ ដែលមាន ទីតាំងស្ថិតនៅភូមិស្វាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ជាកម្មសិទ្ធិរបស់ភាគីដើមចោទ ឈ្មោះ [redacted] វឌ្ឍនា , ៣.បង្គាប់ឲ្យរុះរើរាល់សំណង់ទាំងអស់ដែលភាគីចុងចម្លើយឈ្មោះ [redacted] យូលីម និង ឈ្មោះ [redacted] ស៊ីថាន បានសាងសង់នៅលើដី មានទំហំ ១៣ ម៉ែត្រ x ៦៥ ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិស្វាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង , ៤. បង្គាប់អោយសហចុងចម្លើយឈ្មោះ [redacted] យូលីម និង ឈ្មោះ [redacted] ស៊ីថាន ប្រគល់ការកាន់កាប់លើដី ដែល មានទំហំ ១៣ម៉ែត្រ x ៦៥ម៉ែត្រដែលមានទីតាំងស្ថិតនៅភូមិស្វាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ឲ្យមកភាគីដើមចោទវិញ , ៥.បង្គាប់ឲ្យចុងចម្លើយសងជំងឺចិត្ត ការខាតបង់ពេលវេលា និងសេវាកម្មច្បាប់ សរុបទឹកប្រាក់ USD ១០.០០០ (មួយម៉ឺនដុល្លារអាមេរិក) មកឲ្យដើមចោទឈ្មោះ [redacted] វឌ្ឍនា និង ៦.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ដោយអះអាងថា ដីវិវាទទំហំ ១៣ម៉ែត្រ គុណនឹង ៦៥ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិស្វាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង គឺជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] វឌ្ឍនា ហៅ [redacted] វណ្ណៈ ដោយមានប្រវត្តិនិងកិរិយាកាន់កាប់តាំងពីឆ្នាំ១៩៧៩ តាមរយៈចំណារបញ្ជាក់ប្រវត្តិនៃការកាន់កាប់ដីរបស់ដើមចោទ និងកាន់កាប់ដោយមានការដឹងឮពីក្នុងពាក្យស្នើសុំកាន់កាប់ដីធ្លីចុះថ្ងៃ២៣ ខែកញ្ញា ឆ្នាំ២០០៦ របស់ដើមចោទ និងលិខិតបញ្ជាក់ប្រវត្តិដីចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១២ របស់មេឃុំរកា ឈ្មោះ [redacted] ហាយ ហើយក្រោយមកមានការចាក់ដីបន្ថែមសង់ផ្ទះដែលមានសសរថ្ម ជញ្ជាំងក្តារ ទ្វារបង្អួចឈើ និងប្រក់ស័ង្កសី និងបានធ្វើរបងដែកដាក់នៅច្រកចេញចូលដីដោយដាក់ក្បាច់ឈ្មោះ NAK និងសង់ព័ទ្ធដោយរបងឈើ ព្រមទាំងមានបោះបង្គោលថ្មសម្គាល់ព្រំដីផងដែរនោះ នោះឃើញថា ពុំមានលក្ខណៈត្រឹមត្រូវឡើយ ដោយហេតុថាតាមរយៈការពិនិត្យទៅលើឯកសារដែលមានក្នុងសំណុំរឿង គឺពុំមានកស្តុតាងគតិយុត្តច្បាស់លាស់ណាមួយដែលអាចបញ្ជាក់បានអំពីភាពជាម្ចាស់កម្មសិទ្ធិរបស់ដើមចោទលើដីវិវាទដែលមានទំហំ ១៣ ម៉ែត្រ គុណនឹង ៦៥ ម៉ែត្រ មានទីតាំងស្ថិតនៅភូមិស្វាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ។ ម្យ៉ាងវិញទៀត ការដែលដើមចោទបានអះអាងអំពីភាពជាកម្មសិទ្ធិករដោយផ្អែកតែទៅលើ ពាក្យស្នើសុំ



Scanned with CamScanner

កាន់កាប់ដីធ្លីចុះថ្ងៃ២៣ ខែកញ្ញា ឆ្នាំ២០០៦ និងលិខិតបញ្ជាក់ប្រវត្តិដីចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២ របស់មេឃុំរកា ឈ្មោះ [redacted] ហាយ នោះគឺគ្រាន់តែជាលិខិតបញ្ជាក់ដោយពុំមានភាពច្បាស់លាស់ និងពុំមានចុះលេខឡើយ ហេតុនេះ គឺមិនមានអានុភាពគតិយុត្តគ្រប់គ្រាន់ក្នុងការបញ្ជាក់ពីភាពជាកម្មសិទ្ធិករស្របច្បាប់ចំពោះអចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទខាងលើនោះឡើយ។ ដូច្នេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះ មិនពិចារណាលើការស្នើសុំរបស់ដើមចោទឈ្មោះ [redacted] វឌ្ឍនា ហៅ [redacted] វណ្ណៈ នេះទេ។

៤/. នាពេលទាញហេតុផលដោយផ្ទាល់មាត់ សហចុងចម្លើយឈ្មោះ [redacted] យូលីម និងឈ្មោះ [redacted] ស៊ីថាន ស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេច ច្រានចោលពាក្យបណ្ដឹងចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] វឌ្ឍនា ហៅ [redacted] វណ្ណៈ , ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ និងស្នើសុំឲ្យសងសំណងសេវាមេធាវី ជំងឺចិត្ត ផលប៉ះពាល់លើកិត្តិយសសេចក្ដីថ្លៃថ្នូរ ពេលវេលានិងសោហ៊ុយ ផ្សេងៗ ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លាអាមេរិក។

ក្រុមប្រឹក្សាជំនុំជម្រះ យល់ឃើញថា មានលក្ខណៈត្រឹមត្រូវ ព្រោះតាមបង្កាន់ដៃទទួលពាក្យលេខ៥៥៩៤, លេខ៥៥៩៥ ចុះថ្ងៃទី២០ខែតុលាឆ្នាំ១៩៩០បង្កាន់ដៃបង់ប្រាក់ បញ្ជាក់ឲ្យឃើញថា ចុងចម្លើយឈ្មោះ [redacted] យូលីម ជាម្ចាស់កម្មសិទ្ធិលើដីវិវាទនោះ ប្រាកដមែន។ ដោយឡែកចំពោះការស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឲ្យដើមចោទសងសំណងសេវាមេធាវី ជំងឺចិត្ត ផលប៉ះពាល់លើកិត្តិយសសេចក្ដីថ្លៃថ្នូរ ពេលវេលានិងសោហ៊ុយ ផ្សេងៗ ទៅចុងចម្លើយចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក នោះឃើញថា ពុំមានលក្ខណៈត្រឹមត្រូវឡើយ ដោយហេតុថា ចាប់តាំងពីនីតិវិធីជំនុំជម្រះលើទី១ របស់សាលាដំបូងខេត្តព្រៃវែង ភាគីសហចុងចម្លើយឈ្មោះ [redacted] យូលីម និងឈ្មោះ [redacted] ស៊ីថាន ពុំបានដាក់បណ្ដឹងតបដើម្បីជាកម្មវត្ថុនៃការទាមទារនោះទេ ហេតុនេះគប្បីក្រុមប្រឹក្សាជំនុំជម្រះមិនពិចារណាលើការស្នើសុំនេះទេ។

៥/. អនុលោមតាមមាត្រា ៦៤ កថាខណ្ឌ ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

## <u>សេចក្ដីសម្រេចបញ្ចប់</u>

១/. ទទួលជំនុំជម្រះសំណុំរឿងរដ្ឋប្បវេណីលេខ ១១៨ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៣ របស់សាលាឧទ្ធរណ៍ភ្នំពេញ តាមអំណាចសាលដីការដ្ឋប្បវេណីលេខ ៣៤៨ «ណ» ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២ របស់តុលាការកំពូល។

២/. ច្រានចោលការទាមទាររបស់ដើមចោទឈ្មោះ [redacted] វឌ្ឍនា ហៅ [redacted] វណ្ណៈ តាមពាក្យបណ្ដឹងចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ។

៣/. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ ។



Scanned with CamScanner

សាលដីកានេះប្រកាសជាសាធារណៈថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣ បើកសិទ្ធិប្ដឹងសាទុក្ខរយៈពេល០១ខែ គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ ។

**ក្រឡាបញ្ជី** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

---

**បានឃើញ**
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃអង្គារ ៨រោច ខែកត្ដិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៣
**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner